# មតិរបស់អ្នកច្បាប់ម្នាក់

នយោបាយគឺជានាមថ្មីនៃសោកនាកម្ម។ គ្មានពេលណា ដែលការអះអាងរបស់ណាប៉ូឡេអុង នេះមានភាពត្រឹមត្រូវដូចនាអំលុងពេលសង្គ្រាមត្រជាក់នោះទេ។ នៅពេលដែលប្រទេសតតិយលោកត្រូវប្រឈមមុខនឹងការគំរាមកំហែងនឹងចំបាំងអណានិគមបរទេស គេគ្មានជម្រើសអ្វីក្រៅពីការចុះចូលនឹងពួកចក្រពត្តិ ឬមួយក៏ចុះចូលនឹងពួកកុំម្មុយនីស្ត ឬពួកផ្តាច់ការនិយមនោះទេ។ គឺក្នុងស្ថានភាពនេះហើយដែលលោកខៀវ-សំផន, បញ្ញាជនក្មេងខ្ចីប្រកបដោយចិត្តមនុស្សធម៌ត្រូវប្រឈមមុខនាឆ្នាំ ១៩៦៧ នៅពេលដែលគាត់ត្រូវទទួលនូវការគំរាមកំហែងតាមចាប់ពីរដ្ឋាភិបាល, គាត់បានភៀសខ្លួនទៅចុះចូលនឹងពួក(ខ្មែរ)ក្រហម ដែលពួកនេះកំពុងតែរៀបចំចលនាតស៊ូរំដោះជាតិប្រឆាំងនឹងការប៉ុនប៉ងរបស់អាមេរិកកាំង ដែលមានបំណងយកប្រទេសខ្មែរជាទីលានប្រយុទ្ធប្រឆាំងនឹងវៀតណាម។

ជ័យជំនះដែលបានមកដោយការតស៊ូដ៏ស្វិតស្វាញមួយ, ដែលមិនមែនជារបស់ លោក ខៀវ-សំផន, មានការក្រពុលមុខជាខ្លាំង។ ក្រពុលមុខជាខ្លាំងនឹងអំណាចដ៏ធំធេងជាយថាហេតុ, ក្រពុលមុខជាខ្លាំងចំពោះគ្រោះថ្នាក់ ដែលគំរាមកំហែងរដ្ឋាភិបាលបដិវត្តន៍ដ៏ក្មេងខ្ចី នោះគឺ វត្តមាននៃភ្នាក់ងារសម្ងាត់អាមេរិកកាំងដែលបង្កប់ខ្លួនពាសពេញទីក្រុងភ្នំពេញ និងមួយទៀតគឺឧបាយកលយួនដែលប៉ុនប៉ងរៀបចំសហព័ន្ធឥណ្ឌូចិនឡើងវិញក្រោមការដឹកនាំរបស់គេ ដូចកាលពីសម័យអនានិគមបារាំងដែរ។ ដើម្បីប្រឈមមុខនឹងបញ្ហានេះក្រុមដឹកនាំ(ខ្មែរ)ក្រហមពុំបានព្យាយាមពន្យល់បញ្ចុះបញ្ចូលគេឲ្យគាំទ្រខ្លួនទេបែរជារត់រកវិធានការបង្ខិតបង្ខំរហូតកើតមានជាឧក្រិដ្ឋកម្មទៅលើមនុស្សជាតិ។ ចំពោះឧក្រិដ្ឋកម្មទាំងនោះលោក ខៀវ-សំផន មិនដែលមានចំណែកដោយផ្ទាល់ទេ។ ក្នុងនាមជាមិត្របដិវត្តន៍រួមដំណើរជាមួយក្រុម(ខ្មែរ)ក្រហម លោក ខៀវ-សំផន បានព្យាយាមការពារអធិបតេយ្យភាពដែលរដ្ឋាភិបាលក្មេងខ្ចីទើបទទួលបានលើឆាកអន្តរជាតិ។

តើជំហរនេះវាមានអ្វីខុសប្លែកពីជំហររបស់ស្តេចសីហនុ ដែលគេមានការមន្ទិលយ៉ាងតិចតួចបំផុតចំពោះសម្បទានរបស់ព្រះអង្គនឹងពួកក្រហម ? អ្វីដែលខុសគ្នានោះគឺ ឋានៈសង្គមប៉ុណ្ណោះ ។

ដូច្នេះការចោទប្រកាន់លើរូបលោក ខៀវ-សំផន គឺជាបទឃុបឃិតបែបវត្ថុវិស្ស័យ ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តិដោយអ្នកដទៃក្នុងនាមលោកជាកំពូលអ្នកដឹកនាំរដ្ឋ។ ប៉ុន្តែក្នុងសញ្ញាណនៃបទឃុបឃិតបែបវត្ថុវិស្ស័យនេះ វាគ្មានសុពលភាពតាមច្បាប់ទេ។ ពួកឧត្តមសេនិយសូវៀត ដែលបានខិតខំការពារឯករាជ្យភាពនៃសហភាពសូវៀតប្រឆាំងនឹងអំពើឃោរឃៅរបស់ពួកណាស៊ី មិនដែលត្រូវបានគេចោទប្រកាន់ជាអ្នកឃុបឃិតឧក្រិដ្ឋកម្មជាមួយស្តាលីនទេ។ លោក ស្កាត្ស ជារដ្ឋមន្ត្រីហិរញ្ញវត្ថុរបស់ហ៊ីត្លែរ ហើយក្រោយមកបានធ្វើជាទេសរដ្ឋមន្ត្រីរបស់ហ៊ីត្លែរ រហូតដល់ឆ្នាំ ១៩៤៣ ឬ លោក វ៉ុនប៉ាប៉ុន ដែលបានធ្វើឧបនាយករដ្ឋមន្ត្រី ហើយក្រោយមកធ្វើជារដ្ឋទូតអាល្លឺម៉ង់ ពួកគេត្រូវបាន

តុលាការ នូរ៉ែមប៊ែរ សម្រេចឲ្យរួចខ្លួន។ លោក អាដុល្វ កាឡែង អ្នកបើកបរយន្តហោះរបស់អាល្លឺម៉ង់ណាស៊ី ដែលបានទទួលជ័យជំនះ ១០៣ ដងលើយន្តហោះសម្ពន្ធមិត្រ មិនបានត្រូវតុលាការចោទប្រកាន់ ទេ។

នៅប្រទេសបារាំងគ្មាននរណាមានគំនិតចោទប្រកាន់ លោក អង់ដ្រេ ម៉ាល់រ៉ូ រដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ ឬ លោក ម៉ូរីសគូវដឺ-មើរវិល រដ្ឋមន្ត្រីការបរទេស ថាជាអ្នករួមគំនិតប្រព្រឹត្តិឧក្រិដ្ឋកម្មសង្គ្រាមនៅអាល់ហ្សេរី ទេ។

នៅប្រទេសអង់គ្លេសគ្មាននរណាគិតចោទប្រកាន់លោកឧត្តមសេនីយ ម៉ុងគោមេរី ឬ អង់តូនី-អ៊ិដិន, រដ្ឋមន្ត្រីការបទេស, នឹងអំពើរើសអើងរបស់គាត់ចំពោះជនជាតិដើមនៅប្រទេសអូស្ត្រាលីដែលជាសមាជិកនៃសហព័ន្ធកិម៉ិនវែល។

ដូច្នេះតើគេអាចចោទប្រកាន់លោក ខៀវ-សំផន ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តិដោយបុគ្គលមួយចំនួននៃក្រុមខ្មែរក្រហម ដោយពុំធ្វើការចោទប្រកាន់ទៅលើសហរដ្ឋអាមេរិក ដែលបានប្រើគ្រប់មធ្យោបាយដើម្បីបំផ្លិចបំផ្លាញរដ្ឋអំណាចសីហនុ ដោយគាំទ្ររដ្ឋប្រហាររបស់លោកឧត្តមសេនីយ លន់ នុល ដែលជាមូលហេតុបណ្ដាលឲ្យមានការរីករាលដាលនៃគ្រោះសង្គ្រាមនៅប្រទេសខ្មែរ?

ដើម្បីជាគំរូល្អ, តុលាការមួយត្រូវតែធ្វើការពិនិត្យពិច័យឲ្យបានគ្រប់ជ្រុងជ្រោយនូវអ្វីៗ ដែលគេចោទប្រកាន់ទៅលើពិរុទ្ធជន ហើយគេមិនត្រូវឲ្យមានទម្ងន់អតុល្យភាពក្នុងការវិនិច្ឆ័យនៃការទទួលខុសត្រូវរវាងពិរុទ្ធជនម្នាក់នៅនឹងពិរុទ្ធជនម្នាក់ទៀតឡើយ។

ខែ មិថុនា ឆ្នាំ ២០០៣
ហ្សាក់-វែរហែស

## Préface

La politique est le nom moderne de la tragédie. Jamais cette affirmation de Napoléon n'a été aussi justifiée qu'au temps de la guerre froide. Quand, dans les pays du Tiers Monde menacés de reconquête coloniale, le choix forcé était la soumission à l'impérialisme ou le ralliement au camp socialiste et à la dictature. C'est devant ce choix que Khieu Samphan, jeune intellectuel humaniste, a été placé en 1967 quand, menacé d'arrestation, il a dû se réfugier dans les maquis Khmers Rouges. Ceux-ci menaient alors un combat libérateur contre la volonté américaine de faire du Cambodge, devenu satellite, un champ de bataille contre le Vietnam.

La victoire remportée de haute lutte, la direction Khmer Rouge à laquelle n'appartenait pas Khieu Samphan, a été prise de vertige, vertige du pouvoir absolu et vertige devant les dangers qui continuaient à peser contre le jeune pouvoir révolutionnaire, présence d'agents américains dans Phnom Penh et manoeuvre du grand frère vietnamien pour reconstituer sous sa direction la vieille fédération indochinoise du temps des Français. Pour y faire face, la direction Khmer Rouge a eu recours non à la persuasion mais à la contrainte et finalement à des crimes contre la personne humaine. A ces crimes, Khieu Samphan nia jamais pris de part directe. Compagnon de route des

Khmers Rouges, il s'est efforcé, sur le plan international, de préserver l'indépendance reconquise du jeune État.

Cette question n'a-t-elle pas été aussi, avec les différences liées à leur statut différent, celle du Prince Norodom Sihanouk, peu suspect de sympathies pour les dirigeants Khmers Rouges ?

Le procès d'intention qui est fait à Khieu Samphan serait dès lors d'une complicité objective dans les crimes commis par d'autres, vu ses fonctions au sommet de l'État Mais cette notion de complicité objective n'est pas valide en droit. Les maréchaux soviétiques qui ont défendu l'indépendance de l'URSS contre la barbarie nazie n'ont jamais été considérés comme complices des crimes de Staline. Messieurs Schacht, grand argentier dHitler puis ministre d'État jusqu'en 1943, ou Von Papen, vicechancelier puis ambassadeur du Reich ont été acquitter par le tribunal de Nuremberg et Adolf Galland, as allemand de l'aviation aux 103 victoires sur des avions alliés, n'ajamais été poursuivi.

Personne -n'a jamais eu l'idée en France d'accuser André Malraux, ministre de la culture, ou Maurice Couve de Murville, ministre des affaires étrangères, d'être complice de crimes de guerre commis en Algérie personne en Angleterre n'a jamais mis en cause Maréchal Montgomery ou Sir Anthony Eden, ministre delà affaires étrangères, pour le traitement discriminatoire des Aborigènes en Australie, pays membre Commonwealth.

Par ailleurs, peut-on faire le procès de Monsieur Khieu Samphan pour les crimes commis par certain Khmers Rouges sans faire le procès des responsables américains qui ont tout fait pour miner l'autorité Norodom Sihanouk, soutenir le coup État militaire Général Lon Nol et étendre au Cambodge les malheurs de la guerre.

Pour être pédagogique, un procès doit examiner toutes les circonstances des faits reprochés aux accusés et il ne saurait y avoir en ce domaine des poids différents pour juger de la responsabilité des uns et des autres.

Juin 2003
Jacques Vergès